**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ២៧ មេសា ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
**ថ្ងៃ ខែ ឆ្នាំ (Date):** 27-Apr-2012, 14:36
**CMS/CFO:** Sann Rada

---

**បណ្ដឹងជំទាស់ចំពោះលោកស្រីចៅក្រម SILVIA CARTWRIGHT អនុលោមតាមវិធាន ៣៤ ឬ ជាជម្រើសផ្សេង សំណើសុំការណែនាំ និងបង្គាប់ ឲ្យបញ្ឈប់ និង ឈប់ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* (EX PARTE)**

**និង**

**សំណើសុំឲ្យបញ្ចេញឲ្យដឹងអំពីការប្រាស្រ័យទាក់ទងនានាជាមួយ*តែភាគីម្ខាង* (EX PARTE)**

---

**<u>ដាក់ដោយ÷</u>**

**ក្រុមមេធាវីការពារក្ដី អៀង សារី**

**អាង ឧត្ដម**

Michael G. KARNAVAS

**<u>ចម្លងជូន÷</u>**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង÷**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្ដារ**

ចៅក្រម **យ៉ា សុខន**

០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង ធូ មុន្នី

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

**ជា លាង**

Andrew CAYLEY QC

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្ដី") សូមប្ដឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright អនុលោមតាមវិធាន ៣៤។ បណ្ដឹងជំទាស់នេះត្រូវឡើងជាការចាំបាច់ ដោយសារការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង (ex parte)* រវាងលោកស្រីចៅក្រម Cartwright និងលោក Andrew Cayley QC សហព្រះរាជអាជ្ញាអន្តរជាតិ កំពុងតែបន្តដំណើរការ។ នាពេលថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា កិច្ចប្រជុំជាមួយ*តែភាគីម្ខាង* រវាងព្រះរាជអាជ្ញាមួយរូប និងចៅក្រមមួយរូបនៃអង្គជំនុំជម្រះ "អាចបង្កើតអាការៈបង្ហាញថា សហព្រះរាជអាជ្ញាមានសិទ្ធិមិនត្រឹមត្រូវក្នុងការចូលរួមប្រជុំជាមួយចៅក្រមជំនុំជម្រះ" និងអាចនាំឲ្យមានការប្ដឹងជំទាស់ចៅក្រមបាន[១]។ ដោយមិនយកចិត្តទុកដាក់ដល់យោបល់របស់អង្គជំនុំជម្រះតុលាការកំពូល លោកស្រីចៅក្រម Cartwright បានបន្តប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ទាក់ទិននឹងប្រតិកម្មរបស់លោកស្រីទៅនឹងសេចក្ដីសម្រេចរបស់ អ.ជ.ត.ក។ ការដែលលោកស្រីចៅក្រម Cartwright បានផ្ដល់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មានសិទ្ធិមិនត្រឹមត្រូវក្នុងការចូលរួមប្រជុំជាមួយរូបគាត់ទាក់ទិននឹងប្រតិកម្មរបស់លោកស្រី ទៅនឹងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២ បង្ហាញថា លោកស្រីមានភាពលម្អៀងទៅខាង ក.ស.ព ឬ យ៉ាងហោចណាស់ ក៏បានបង្ហាញពីការស្ដែងឲ្យឃើញអំពីភាពលម្អៀងដែរ។ ជាជម្រើសផ្សេងទៀត ប្រសិនបើបណ្ដឹងនេះមិនបានបំពេញបទដ្ឋានភស្តុតាងគ្រប់គ្រាន់សម្រាប់ប្ដឹងជំទាស់ទេ មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើការណែនាំលោកស្រីចៅក្រម Cartwright និងបង្គាប់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បញ្ឈប់ និងឈប់ ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* របស់ខ្លួនទៀត។ អនុលោមតាមកាតព្វកិច្ចក្នុងការបំពេញការងារដោយយកចិត្តទុកដាក់របស់ខ្លួន[២] មេធាវីការពារក្ដីស្នើសុំបន្ថែមទៀតដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបង្គាប់ឲ្យបញ្ចេញឲ្យដឹងនូវការជួបប្រាស្រ័យទាក់ទងនានា*តែភាគីម្ខាង* រវាងលោកស្រី

---

[១] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីបណ្ដឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារលេខ E137/5/1/3 ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក"), កថាខណ្ឌ ២៤។

[២] មេធាវីការពារក្ដីត្រូវបានតម្រូវឲ្យបំពេញការងារប្រកបដោយការយកចិត្តទុកដាក់ ដើម្បីការពារផលប្រយោជន៍កូនក្ដីរបស់ខ្លួន។ *សូមមើល* សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចំពោះលោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារលេខ E171/2, កថាខណ្ឌ ១២; សេចក្ដីសម្រេចលើបណ្ដឹងរបស់លោក អៀង សារី សុំប្ដឹងជំទាស់លោកចៅក្រម និល ណុន និងបញ្ហាពាក់ព័ន្ធដទៃទៀត, ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ E5 ("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លោកចៅក្រម និល ណុន"), កថាខណ្ឌ ២។

ចៅក្រម Cartwright និងសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ចាប់ពីឆ្នាំថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ មក ដើម្បីសម្រេចថា តើចាំបាច់ត្រូវដាក់សារណាបន្ថែមទៀត ឬយ៉ាងណា។ ជាចុងក្រោយ មេធាវីការពារក្តីសូមលើកឡើងថា អនុលោមតាមវិធាន ៣៤(៦) និងដើម្បីជាប្រយោជន៍យុត្តិធម៌ លោកស្រីចៅក្រម Cartwright ត្រូវតែដកខ្លួនចេញពីការសម្រេចលើបណ្តឹង/សំណើនេះ។

## I. ប្រវត្តិ

១. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានសេចក្តីសម្រេចរបស់ អ.ជ.ត.ក។ កថាខណ្ឌ ២៤ រៀបរាប់ថា៖

> នៅពេលពុំមានមូលដ្ឋានផ្លូវច្បាប់ណាមួយ ទាំងនៅក្នុងឯកសារបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ឬ អាណត្តិរបស់អង្គជំនុំជម្រះ និងការិយាល័យ អ.វ.ត.ក សម្រាប់រៀបចំកិច្ចប្រជុំបែបនេះ តំណាងឱ្យតុលាការនោះ កិច្ចប្រជុំបែបនេះអាចត្រូវបានយល់ឃើញថាមានការជាប់ទាក់ទងទៅនឹងរឿងក្តីណាមួយ ឬ រឿងក្តីទាំងឡាយ ដែលចៅក្រមចូលរួមប្រជុំមានការពាក់ព័ន្ធ។ កិច្ចប្រជុំទាំងនេះអាចបង្កើតជាអាការៈបង្ហាញថា សហព្រះរាជអាជ្ញាមានសិទ្ធិមិនត្រឹមត្រូវក្នុងការចូលរួមប្រជុំជាមួយចៅក្រមជំនុំជម្រះ។ ហេតុដូច្នេះ ដើម្បីចៀសវាងអាការៈបែបនេះ ដែលនាំឱ្យមានបណ្តឹងជំទាស់ចៅក្រម វាទំនងជាមានភាពចាំបាច់ត្រូវពិចារណាសមាសភាពនៃកិច្ចប្រជុំទាំងឡាយ ដែលចៅក្រមជំនុំជម្រះមានបំណងចូលរួមជាមួយនឹងព្រះរាជអាជ្ញា ដោយគួរអនុញ្ញាតឱ្យមានការចូលរួមរបស់អង្គភាពគាំពារការការពារក្តី ឬ សមាជិកនៅក្នុងក្រុមមេធាវីការពារក្តី តាមករណីសមស្រប[៣]។

សេចក្តីសម្រេចរបស់ អ.ជ.ត.ក ត្រូវបានចេញបន្ទាប់ពីរយៈពេល ៦ ខែ គិតចាប់ពីពេលដែលលោក Michiel Pestman សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា បានរកឃើញថា លោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិ លោក Cayley និងលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល បានជួបប្រជុំគ្នាជាទៀងទាត់ដើម្បីពិភាក្សាពីបញ្ហា

---

[៣] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៤។

នានាដែលពាក់ព័ន្ធនឹងតុលាការ[៤]។

២. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ មានដំណឹងថា លោកស្រីចៅក្រម Cartwright នៅតែបន្តការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង*ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley លើបញ្ហានានាដែលពាក់ព័ន្ធនឹងវិវាទនេះ។ រឿងនេះបានលេចចេញនៅពេលលោកស្រីចៅក្រម Cartwright បានផ្ញើសារអេឡិចត្រូនិកមួយដោយអចេតនាទៅឈ្មោះបុគ្គលិកត្រូវទទួលដំណឹងអំពីសំណុំរឿងពោលគឺ បុគ្គលិក អ.វ.ត.ក ទាំងអស់ ដែលត្រូវជូនដំណឹង នៅពេលមានឯកសារត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿង ០០២។ សារអេឡិចត្រូនិករបស់លោកស្រីចៅក្រម Cartwright មានខ្លឹមសារថា៖

> តាមពិតខ្ញុំបានកំពុងព្យាយាមសម្លឹងមើលចំណុចស្រាលជាងនេះប៉ុណ្ណោះ។ ដូចលោកដឹងស្រាប់ហើយ Andrew ខ្ញុំកំពុងតែពិចារណាយ៉ាងយកចិត្តទុកដាក់ចំពោះជំហររបស់ខ្ញុំ។ ខ្ញុំមិនត្រូវសម្រេចសេចក្តីដោយប្រញាប់ប្រញាលនោះទេ។ [sic]
> ពីខ្ញុំ Silvia

---

[៤] *សូមមើល* សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Silvia Cartwright សហព្រះរាជអាជ្ញាបរទេស និងអនុប្រធានរដ្ឋបាល, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137/1; បណ្តឹងជំទាស់ផ្តាច់ជាបន្ទាន់ចំពោះចៅក្រម Cartwright, ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137/2, កថាខណ្ឌ ១៥; សំណើរបស់លោក អៀង សារី ស្នើឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ ("សំណើសុំការស៊ើបអង្កេត"); ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹង ១) សំណើជាបន្ទាន់របស់ នួន ជា សុំប្តឹងជំទាស់លោកស្រីចៅក្រម Cartwright និង ២) សំណើរបស់ អៀង សារី សុំឱ្យស៊ើបអង្កេតទៅលើការប្រាស្រ័យទាក់ទង*តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត, ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារលេខ E137/4; សេចក្តីសម្រេចលើបណ្តឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារលេខ E137/5 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"); បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E137/5/1/1 ("បណ្តឹងសាទុក្ខ"); ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E137/5/1/2; សេចក្តីសម្រេចរបស់ អ.ជ.ត.ក។

៣. នៅថ្ងៃដដែលនោះ មេធាវីការពារក្តីបានផ្ញើសារអេឡិចត្រូនិកមួយទៅអ្នកស្រី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងថា៖

> ព្រឹកមិញនេះ យើងខ្ញុំបានទទួល (ប្រហែលដោយសារកំហុសឆ្គង) សារអេឡិចត្រូនិកមួយច្បាប់ពីលោកស្រីចៅក្រម Silvia Cartwright ដែលមានបំណងផ្ញើជូនអ្នកទទួលឈ្មោះ "Andrew[”] ...
>
> សម្រាប់មូលហេតុច្បាស់លាស់ទាំងអស់ យើងខ្ញុំស្នើសុំឱ្យមានបញ្ជាក់ឱ្យច្បាស់ថាតើឈ្មោះ Andrew អាចជានរណា។ ប្រសិនបើអ្នកទទួលនោះជាលោក Andrew Cayley ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិនោះ សារអេឡិចត្រូនិកប្រាកដជានាំឱ្យមានការកង្វល់មិនខាន ជាពិសេសទាក់ទិននឹងសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានគូសបញ្ជាក់នូវភាពចាំបាច់ក្នុងការបញ្ចៀស "អាការៈបង្ហាញថាសហព្រះរាជអាជ្ញាមានសិទ្ធិមិនត្រឹមត្រូវក្នុងការចូលរួមប្រជុំជាមួយចៅក្រមជំនុំជម្រះ"។ យើងខ្ញុំសូមអភ័យទោសប្រសិនបើការលើកឡើងបែបនេះពុំគប្បី ប៉ុន្តែក្នុងគោលបំណងបំពេញកាតព្វកិច្ចការងារប្រកបដោយការយកចិត្តទុកដាក់នោះ យើងមានកាតព្វកិច្ចក្នុងការស្រាវជ្រាវលើបញ្ហានេះ។

៤. នៅថ្ងៃ សុក្រ ទី ២០ ខែ មេសា ឆ្នាំ ២០១២ អ្នកស្រី Lamb បានឆ្លើយតបជាមួយ*តែភាគីម្ខាង* មកមេធាវីការពារក្តី ថា៖

> នាងខ្ញុំបានទទួលសំណើឱ្យផ្តល់ជូនព័ត៌មានខាងក្រោមដល់លោក ជាការឆ្លើយតបទៅនឹងសារអេឡិចត្រូនិកដែលលោកបានផ្ញើមកនាងខ្ញុំកាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២៖
>
> "សារអេឡិចត្រូនិកដែលបានផ្ញើចេញការពីម្សិលមិញមានបំណងផ្ញើជូនអ្នកទទួលមួយចំនួន រួមមាន អនុប្រធានការិយាល័យរដ្ឋបាល និងលោក Andrew Cayley ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ។
>
> សារនោះមួយផ្នែកគឺជាការសង្ខេបនៃកិច្ចពិភាក្សារវាង លោកស្រីចៅក្រម Cartwright លោក Cayley និងលោក Rosandhaug ពាក់ព័ន្ធនឹងប្រតិកម្មសមស្របទៅនឹង សេចក្តីសម្រេចរបស់ អ.ជ.ត.ក នាពេលថ្មីៗនេះ ដែលបដិសេធបណ្តឹងសាទុក្ខមួយប្រឆាំងនឹងការបដិសេធមិនឱ្យលោកស្រីចៅក្រម Cartwright ចូលរួមជំនុំជម្រះ។ ការប្រជុំរៀបចំ

សវនាការ ដែលត្រូវបានប្តឹងសុំឱ្យបដិសេធមិនឱ្យលោកស្រីចៅក្រមចូលរួមនោះ ត្រូវបានធ្វើឡើងទៅតាមសំណើរបស់ការិយាល័យកិច្ចការច្បាប់ តែអនុលោមតាមយោបល់របស់ អ.ជ.ត.ក គេបានសម្រេចមិនបន្តកិច្ចប្រជុំនោះទៀតទេ។

បញ្ហាស្តីពីការរៀបចំសវនាការនាពេលខាងមុខ នឹងត្រូវដោះស្រាយដោយផ្ទាល់ជាមួយការិយាល័យរដ្ឋបាលតែម្តង"។

៥. នៅថ្ងៃដដែលនោះ មេធាវីការពារក្តីបានបញ្ជូនសារអេឡិចត្រូនិករបស់អ្នកស្រី Lamb ដល់ភាគីដទៃទៀត។ មេធាវីការពារក្តីបានកត់សម្គាល់ថា ដោយខ្លួនជាភាគីតែមួយគត់ ដែលបានទទួលសារអេឡិចត្រូនិករបស់អ្នកស្រី Lamb នេះ ខ្លួនយល់ឃើញថា ភាគីទាំងអស់គួរតែត្រូវបានចម្លងជូនដើម្បីធ្វើឱ្យមានតម្លាភាព។

## II. បញ្ហាបឋម ៖ ពេលវេលាសមស្របនៃបណ្តឹង

៦. វិធាន ៣៤(៣) តម្រូវថា បណ្តឹងជំទាស់ចិត្តត្រូវតែដាក់នៅពេលភាគីបានដឹងពីមូលដ្ឋាននានានៃបញ្ហានោះភ្លាម។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក អនុញ្ញាតឱ្យប្តឹងជំទាស់ចិត្តនៅពេលលោកស្រីចៅក្រម Cartwright និង លោក Cayley នៅតែបន្តការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង*ទៀត[៥]។ ដូចដែលបានបង្ហាញជូនក្នុងចំណុចប្រវត្តិខាងលើរួចមកហើយ មេធាវីការពារក្តីបានបំពេញការងារយ៉ាងលឿន។ មេធាវីការពារក្តីបានទាក់ទងជាមួយអ្នកស្រី Lamb នៅពេលខ្លួនបានទទួលសារអេឡិចត្រូនិករបស់លោកស្រីចៅក្រម Cartwright ភ្លាម ហើយបណ្តឹង/សំណើនេះត្រូវបានបញ្ជូនទៅបកប្រែជាភាសាខ្មែរក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមេធាវីការពារក្តីបានដឹងអំពីមូលដ្ឋាននានានៃបញ្ហានេះភ្លាម។ ហេតុនេះ បណ្តឹងនេះបានដាក់ទៅតាមពេលវេលាកំណត់។

## III. បណ្តឹងជំទាស់ចិត្ត

៧. សារអេឡិចត្រូនិករបស់លោកស្រីចៅក្រម Cartwright កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ គឺជាការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley

---

[៥] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៤។

ទាក់ទិននឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២។ លោកស្រីចៅក្រម Cartwright កំពុងចែករំលែកព័ត៌មានជាមួយសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ដែលមានវត្តមាន និង បន្តមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ ទាក់ទិននឹងប្រតិកម្ម របស់លោកស្រីចំពោះយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដីនេះ។ សារអេឡិចត្រូនិករបស់លោកស្រីចៅក្រម Cartwright បង្ហាញពីការសន្ទនាជាមួយ *តែភាគីម្ខាង* ទាក់ទិននឹង បែបបទជាយុទ្ធសាស្ត្រ និងជាយុទ្ធវិធី អំពីរបៀបបន្តការងារបន្ទាប់ពីមានសេចក្ដីសម្រេចរបស់ អ.ជ.ត.ក[៦] រួចហើយនោះ។ លក្ខណៈនៃទំនាក់ទំនងរបស់លោកស្រីចៅក្រម Cartwright ជាមួយ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បង្ហាញពីភាពលម្អៀងជាក់ស្ដែង ឬយ៉ាងហោចណាស់ ជាការស្ដែងឲ្យឃើញអំពីភាពលម្អៀងដែរ។

៨. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានព្រមានលោកស្រីចៅក្រម Cartwright រួចមកហើយថា ការបន្តការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* ជាមួយលោកសហ ព្រះរាជអាជ្ញាអន្តរជាតិលោក Cayley អាចនាំឲ្យមានការប្ដឹងជំទាស់ចិត្តនាពេលអនាគត។ ការពិត អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញការព្រួយបារម្ភថា ការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* អាចបង្ហាញពី "អាការៈនៃសិទ្ធិមិនត្រឹមត្រូវ"[៧] ដោយបានចេញសេចក្ដីណែនាំរបស់ខ្លួន បន្ទាប់ពីមានវិវាទរយៈពេល ៦ ខែ និងបានពន្យល់ដោយសង្ខេបទាក់ទិននឹងបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹង ការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងចៅក្រមជំនុំជម្រះ និងសហព្រះរាជអាជ្ញារូបនេះ។

---

[៦] លោកស្រីចៅក្រម Cartwright ទំនងជាយោងទៅការសន្ទនានេះនៅក្នុងសារអេឡិចត្រូនិករបស់គាត់ ដោយបង្ហាញថា សហ ព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដឹងហើយថា លោកស្រីចៅក្រមកំពុងពិចារណាយ៉ាងយកចិត្តទុកដាក់អំពី ជំហររបស់ខ្លួន។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់អ្នកស្រី Lamb ផ្ញើជូនមេធាវីការពារក្ដីនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១២ ដោយបានទទួលស្គាល់ថា "សារនោះមួយផ្នែកគឺជាការសង្ខេបនៃកិច្ចពិភាក្សារវាងលោកស្រីចៅក្រម Cartwright លោក Cayley និងលោក Rosandhaug ពាក់ព័ន្ធនឹងប្រតិកម្មសមស្របទៅនឹងសេចក្ដីសម្រេចរបស់ អ.ជ.ត.ក នាពេលថ្មីៗនេះ ដែលមានបណ្ដឹងសាទុក្ខមួយប្រឆាំងនឹងការបដិសេធមិនឲ្យលោកស្រីចៅក្រម Cartwright ចូល រួមជំនុំជម្រះត្រូវបានបដិសេធចោល"។ ដើម្បីបញ្ចៀសនូវការមន្ទិលសង្ស័យ បណ្ដឹងសាទុក្ខត្រូវបានធ្វើឡើងប្រឆាំងនឹងការ ជំទាស់ក្នុងការស៊ើបអង្កេតពីការប្រព្រឹត្តិរបស់លោកស្រី Cartwright មិនមែនជាបណ្ដឹងជំទាស់ចិត្តទេ។ *សូមមើល* សេចក្ដី សម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ១២, ១៦។

[៧] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៤។

៩. ការព្រមានរបស់អង្គជំនុំជម្រះតុលាការកំពូលបានឆ្លុះបញ្ចាំងអំពីការសង្កេតរបស់អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងដែលថា នៅពេលដែលការប្រាស្រ័យទាក់ទងរវាងសហព្រះរាជអាជ្ញាមួយរូប និងចៅក្រមមួយរូប មិនពាក់ព័ន្ធនឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីក្នុងរឿងក្ដីណាមួយនោះ ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* បែបនេះ ត្រូវបានចាត់ទុកថា មិនបង្ហាញឱ្យឃើញអំពីភាពលម្អៀង ឬការស្ដែងឲ្យឃើញអំពីភាពលម្អៀងឡើយ[៨]។ ដូច្នេះ យើងអាចនិយាយបានថា នៅពេលការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង ពាក់ព័ន្ធ* នឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីនោះ ប្រការនេះ*អាច* បង្ហាញពីភាពលម្អៀង ឬការស្ដែងឲ្យឃើញអំពីភាពលម្អៀងដែរ។

១០. ផ្អែកលើអង្គហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការសន្និដ្ឋានដោយមានមូលដ្ឋានជាក់លាក់មួយចំនួនថា៖

(១) លោកស្រីចៅក្រម Cartwright បានអនុញ្ញាតឲ្យមានស្ថានភាពមួយ ដែលបង្ហាញឲ្យឃើញច្បាស់ដែលថា ក.ស.ព មានសិទ្ធិក្នុងកម្រិតមួយ ដែលចៅក្រមជំនុំជម្រះនឹងប្រាស្រ័យទាក់ទងការងារជាមួយ ក.ស.ព ពាក់ព័ន្ធនឹងប្រតិកម្មសមស្របចំពោះយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២ ដោយពុំបានចែករំលែកព័ត៌មាននេះជាមួយភាគីដទៃទៀត។

(២) លោកស្រីចៅក្រម Cartwright មិនយកចិត្តទុកដាក់ចំពោះសេចក្ដីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងអនុភាពផ្លូវច្បាប់នៃការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង*។

(៣)នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ លោកស្រីចៅក្រម Cartwright បានដឹងថា ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* ជាមួយសហព្រះរាជអាជ្ញាមួយរូប អាចនឹងនាំឲ្យមានបណ្ដឹងជំទាស់ចិត្តដល់រូបគាត់។ និង

---

[៨] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៦។

(៤) នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ លោកស្រីចៅក្រម Cartwright បានដឹងថា ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* ដែលពាក់ព័ន្ធនឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ អាចបង្ហាញពីភាពលម្អៀង ឬការស្តែងឲ្យឃើញអំពីភាពលម្អៀង។

១១. មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកការណែនាំពីវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ នៅពេលមានភាពមន្ទិលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តនីតិវិធីដែលមានស្រាប់។ ប្រសិនបើភាពមន្ទិលនេះកើតមានពាក់ព័ន្ធនឹងការអនុវត្តវិធាន ៣៤ ក្នុងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាថាអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTR ក្នុងសំណុំរឿង *Karemera* បានសម្រេចថាទំនាក់ទំនងជាប្តីប្រពន្ធរបស់រដ្ឋអាជ្ញាម្នាក់ជាមួយចៅក្រមជំនុំជម្រះម្នាក់ ដែលធ្វើឲ្យចៅក្រមរូបនោះខកខានពុំបានប្រកាសអំពីប្រភេទនៃទំនាក់ទំនងនេះឡើយ រហូតទាល់តែមេធាវីការពារក្តីបានលើកបញ្ហានេះជាចំហរ ថាជាការពិចារណាពាក់ព័ន្ធ នៅពេលសម្រេចថាតើមានការលេចឡើងនូវភាពលម្អៀងដែរឬទេ[៥]។ ទំនាក់ទំនងរបស់ចៅក្រម Cartwright ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានវិវឌ្ឍន៍ដល់កម្រិតមួយដែលពួកគាត់បានចែករំលែកព័ត៌មាន *ជាមួយភាគីតែម្ខាង* ពាក់ព័ន្ធនឹងយុត្តិសាស្ត្រនៃសំណុំរឿង ០០២។ ដោយសាររបស់ចៅក្រម Cartwright ខកខានពុំបានប្រកាសអំពីលក្ខណៈនៃការចូលរួមរបស់គាត់ក្នុងជំនួប *ជាមួយភាគីតែម្ខាង* ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley មុនពេលមេធាវីការពារក្តីលើកបញ្ហានេះឡើង វិធាននីតិវិធីដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ បង្ហាញថា ទង្វើរបស់ចៅក្រម Cartwright នាំឲ្យមានការលេចឡើងយ៉ាងហោចណាស់ក៏ការលេចឡើងនូវភាពលម្អៀងដែរ។

១២. តាមការដឹងរបស់មេធាវីការពារក្តី ទោះបីជាពុំមានក្រុមមេធាវីការពារក្តីណាមួយបានព្យាយាមទាក់ទងការងារ *ជាមួយភាគីតែម្ខាង* ជាមួយសមាជិកនៃអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានព្រមានមេធាវី

---

[៥] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Karemera,* លេខសំណុំរឿង ICTR-98-44-AR 15ស្ទួន2, សំអាងហេតុសម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ទាក់ទិននឹងការបន្តកិច្ចដំណើរការនីតិវិធីជាមួយចៅក្រមជំនួស និងលើសំណើរបស់ Nziorera សុំការអនុញ្ញាតដើម្បីពិចារណាលើភស្តុតាងថ្មី, ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ៦៧។

ការពារក្តី ចំពោះការទាក់ទងដោយតម្លាភាពជាមួយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងបញ្ហារដ្ឋបាល។ ជាក់ស្តែង នៅពេលអ្នកស្រី Lamb បានផ្តល់ព័ត៌មានស្តីពីកាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ *ជាមួយភាគីតែម្ខាង* ទៅភាគីមួយចំនួន មេធាវីការពារក្តីបានផ្ញើសារអេឡិចត្រូនិកមួយច្បាប់ដើម្បីតវ៉ា និងបានចម្លងជូនអង្គជំនុំជម្រះសាលាដំបូង។ ដោយបានជំទាស់ទៅនឹងការដែលមេធាវីការពារក្តីបានចម្លងសារអេឡិចត្រូនិកជូនចៅក្រម (ដែលមេធាវីការពារក្តីបានធ្វើដើម្បីជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងអំពីលក្ខណៈមិនសមស្របនៃការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* របស់អ្នកស្រី Lamb ចៅក្រម Cartwright បានស្នើសុំឱ្យអ្នកស្រី Lamb៖

> ជម្រាបមកលោក Karnavas ថា ចៅក្រមមានការព្រួយបារម្ភថា គាត់បន្តដាក់បញ្ចូលឈ្មោះពួកគាត់នៅក្នុងលិខិតទាក់ទងការងាររបស់គាត់ ដោយផ្តល់ភាពសមហេតុផលតាមរយៈការនិយាយថានេះគឺជារឿងសំខាន់។ ជាការពុំសមស្រប ដែលគាត់ប្រើប្រាស់ [sic] ការប្រាស្រ័យទាក់ទងការងារដោយផ្ទាល់ នៅពេលមានភាពច្បាស់លាស់ដែលថា លោកត្រូវបាន [អង្គជំនុំជម្រះសាលាដំបូង] ផ្ទាល់ ស្នើសុំឱ្យធ្វើការប្រាស្រ័យទាក់ទងការងារក្រៅផ្លូវការជាមួយភាគី[១០]។

១៣. ស្រដៀងគ្នានេះ នៅពេលដែលមេធាវីការពារជនជាប់ចោទ នួន ជា បានសរសេរលិខិតទៅចៅក្រមប្រធាន និល ណុន ពាក់ព័ន្ធនឹងកង្វះការផ្តល់សេវាបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារ នៅឯកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ លោក Rosandhaug បានណែនាំមិនឱ្យប្រាស្រ័យទាក់ទងការងារផ្ទាល់ជាមួយចៅក្រម "ជាលក្ខណៈបុគ្គល ឬជារួម" ឡើយ ហើយ "គ្មានការប្រាស្រ័យទាក់ទងការងារផ្ទាល់ខ្លួនណាមួយ [ជាមួយចៅក្រម] ត្រូវបានអនុញ្ញាតឡើយ"[១១]។

---

[១០] *សូមមើល* សារអេឡិចត្រូនិកពីចៅក្រម Cartwright ជូនចំពោះ Michael G. Karnavas, ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។

[១១] សារអេឡិចត្រូនិកពី Knut Rosandhaug ទៅ Andrew Ianuzzi, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១, "ដោយយោងតាមលិខិតឆ្លើយឆ្លងខាងក្រោមផ្ញើផ្ទាល់ទៅចៅក្រម ខ្ញុំត្រូវបានស្នើសុំឱ្យ ហើយដូច្នេះ សូមបញ្ជាក់ឡើងវិញអំពីសារអេឡិចត្រូនិករបស់ខ្ញុំ ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទៅសហមេធាវីរបស់អ្នក ដែលខ្ញុំរំឭកគាត់ "...មិនឱ្យប្រាស្រ័យទាក់ទងការងារដោយផ្ទាល់ជាមួយ [ចៅក្រម] ជាលក្ខណៈបុគ្គល ឬជារួម..." និងអំពី "...នីតិវិធីសម្រាប់ការដាក់សំណើ ឬពាក្យសុំទាក់ទិននឹងកិច្ចដំណើរការនីតិវិធី ហើយពុំមានការប្រាស្រ័យទាក់ទងការងារផ្ទាល់ខ្លួនណាមួយត្រូវបានអនុញ្ញាតឡើយ"។

១៤. ចៅក្រម Cartwright ពុំអនុញ្ញាតឲ្យមេធាវីការពារក្ដីប្រាស្រ័យទាក់ទងការងារជាមួយគាត់ដោយផ្ទាល់ *ក្នុងចំណោមភាគីទាំង* ហើយក៏ពុំឯកភាពទៅនឹងការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* រវាងមេធាវីការពារក្ដី និងអង្គជំនុំជម្រះសាលាដំបូងឡើយ។ ប៉ុន្តែ គាត់ពុំមានបញ្ហាអ្វីជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដែលបានទាក់ទងគាត់ជាលក្ខណៈឯកជនឡើយ ហើយបានឆ្លើយតបវិញជាលក្ខណៈឯកជនដែរ ដើម្បីចែករំលែកគំនិតយោបល់ដែលទាក់ទិននឹងសំណុំរឿង ០០២ និងអាចប៉ះពាល់ដល់ប្រយោជន៍របស់ភាគីផង។ ការយកចិត្តទុកដាក់ជាមួយភាគីដោយមិនស្មើភាពនេះមានភាពច្បាស់ក្រឡែត។

១៥. មានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ប្ដឹងជំទាស់ចៅក្រម ដោយផ្អែកលើអង្គហេតុដែលគេបានដឹង[១២]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ការដែលសហព្រះរាជអាជ្ញាទទួលបានសិទ្ធិមិនត្រឹមត្រូវក្នុងការជួបប្រជុំជាមួយចៅក្រមជំនុំជម្រះ" អាចនាំឲ្យមានបណ្ដឹងជំទាស់[១៣]។ អង្គជំនុំជម្រះសាលាដំបូងបានស្នើថា ការប្រាស្រ័យទាក់ទងការងាររវាងព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះទាក់ទិននឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងមួយ អាចបង្ហាញអំពីភាពលម្អៀង ឬការស្ដែងចេញនៃភាពលម្អៀង[១៤] ហេតុដូច្នេះបានបំពេញលក្ខខណ្ឌក្នុងការប្ដឹងជំទាស់ចៅក្រម[១៥]។

---

[១២] ភាគីមួយដែលស្នើសុំប្ដឹងជំទាស់ចំពោះចៅក្រមត្រូវ "បង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និងត្រូវមានភស្តុតាងគាំទ្រ" នៅក្នុងពាក្យសុំប្ដឹងជំទាស់របស់ខ្លួន។ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចំពោះចៅក្រម Silvia Cartwright, ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E171/2, កថាខណ្ឌ ១៣។

[១៣] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ២៤។

[១៤] *សូមមើល* សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៦។

[១៥] វិធាន ៣៤(២) ចែងថា៖ "ភាគីអាចធ្វើបណ្ដឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលក្នុងករណីណាមួយដែលចៅក្រមរូបនោះមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិ របស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង"។ ដោយបកស្រាយវិធាននេះ យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានទទួលស្គាល់លក្ខខណ្ឌដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានចែង និងបានសម្រេចថា៖ "ចៅក្រមណាម្នាក់លម្អៀង ប្រសិនបើមានការបង្ហាញថា ភាពលម្អៀងជាក់ស្ដែងកើតមាន។ មានការស្ដែងចេញនូវភាពលម្អៀងប្រសិនបើ៖ - ចៅក្រមណាម្នាក់គឺជាភាគីនៃសំណុំរឿង ឬមានផលប្រយោជន៍ហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិ នៅក្នុងលទ្ធផលនៃសំណុំរឿង ឬប្រសិនបើសេចក្ដីសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឲ្យមានការលើកតម្កើងនៃបុព្វហេតុមួយដែលចៅក្រមនោះជាប់ពាក់ព័ន្ធ រួមជាមួយនឹងភាគីណាមួយ។ ក្រោមកាលៈទេសៈបែបនេះ ការដកហូតសិទ្ធិរបស់

សារអេឡិចត្រូនិករបស់ចៅក្រម Cartwright ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ បង្ហាញភស្តុតាងអំពីការយកចិត្តទុកដាក់របស់គាត់ជាមួយភាគីដោយពុំស្មើភាព និងភាពលម្អៀងទៅរក ក.ស.ព បើប្រៀបនឹងភាគីផ្សេងៗទៀត ទាក់ទិននឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងនេះ[១៦]។

១៦. ដើម្បីបញ្ចៀសភាពលម្អៀង ឬការស្តែងចេញនូវភាពលម្អៀង ចៅក្រម Cartwright គួរតែបានធ្វើឲ្យប្រាកដថា គ្រប់ការប្រាស្រ័យទាក់ទងការងារតាមរយៈសារអេឡិចត្រូនិក ដែលគាត់បានធ្វើជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ត្រូវបានចម្លងទៅអ្នកតំណាងអង្គភាពគាំពារការការពារក្តី ឬក្រុមមេធាវីការពារក្តី។ ចៅក្រម Cartwright បានទទួលការជូនដំណឹងពីសំណាក់អង្គជំនុំជម្រះតុលាការកំពូលដែលថា ការធ្វើបែបនេះនឹងបញ្ចៀសការធ្វើឲ្យលេចចេញនូវទំនាក់ទំនងមិនស្មើភាព ដែលអាចនាំឲ្យមានបណ្តឹងជំទាស់ចំពោះរូបគាត់។ ផ្ទុយទៅវិញ ចៅក្រម Cartwright បានបន្តប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដដែល។

## IV. សំណើសុំដំណោះស្រាយជាជម្រើសផ្សេងមួយទៀត

១៧. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ថា បទដ្ឋានភស្តុតាងសម្រាប់បណ្តឹងជំទាស់ អនុលោមតាមវិធាន ៣៤ ពុំត្រូវបានបំពេញ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងចេញ

---

ចៅក្រមពីសំណុំរឿងនោះ គឺត្រូវធ្វើជាស្វ័យប្រវត្ត ឬនឹងនាំឲ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ ទទួលព័ត៌មានគ្រប់គ្រាន់ ជឿដោយមានហេតុផលត្រឹមត្រូវថា មានភាពលម្អៀង"។ សេចក្តីសម្រេចលើពាក្យសុំប្តឹងជំទាស់ចំពោះចៅក្រម និល ណុន កថាខណ្ឌ ៦។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវី ជនត្រូវចោទ នួន ជា, ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨, ឯកសារ C11/29, កថាខណ្ឌ ២០-២១ (ដោយប្រដូច "អ្នកសង្កេតការណ៍ប្រកបដោយវិចារណៈញ្ញាណ" ទៅនឹង "បុគ្គលដែលបានទទួលព័ត៌មាន ដែលបានដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងប្រវត្តិនៃសុចរិតភាព និងអនាគតិ ដែលបង្កើតជាផ្នែកមួយនៃប្រវត្តិ និងបានដឹងផងដែរអំពីចំណុចដែលថាអនាគតិ គឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចនានាដែលចៅក្រមសច្ចាតម្កល់")។

[១៦] បណ្តឹងដែលមានភាពស្មានៗ ឬផ្អែកលើ "ការយល់ឃើញ ឬការសង្ស័យថាមានភាពលម្អៀងប៉ុណ្ណោះ" មិនគ្រប់គ្រាន់ឡើយ។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម Silvia Cartwright, ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E171/2, កថាខណ្ឌ ១៣។

សេចក្តីសម្រេចមួយ *ដោយធ្វើការណែនាំដល់* ចៅក្រម Cartwright និង *បង្គាប់* ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ឈប់ និងបញ្ឈប់ការបន្តការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* របស់ពួកគាត់ ហើយការប្រាស្រ័យទាក់ទងការងារទាក់ទិននឹង អ.វ.ត.ក ទាំងអស់នៅថ្ងៃមុខរវាងពួកគាត់ ត្រូវចម្លងទៅសមាជិកមួយរូបនៃអង្គភាពគាំពារការការពារក្តី ឬក្រុមមេធាវីការពារក្តីទៅតាមការសមស្រប។

១៨. សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ហាក់ដូចជាបានផ្តួចផ្តើមផ្ញើសារអេឡិចត្រូនិករបស់គាត់ជាមួយចៅក្រម Cartwright ដើម្បីដឹងអំពីយោបល់របស់ចៅក្រម Cartwright អំពីវិធីដែលគាត់នឹងដោះស្រាយចំពោះយុត្តិសាស្ត្រនៃសំណុំរឿង ០០២ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ ការប្រាស្រ័យទាក់ទងការងារទាំងនេះ បង្ហាញឲ្យឃើញនូវភាពពុំអើពើចំពោះអង្គជំនុំជម្រះតុលាការកំពូល និងគោលការណ៍ក្រមសីលធម៌ ដែលគួរបានចងកាតព្វកិច្ច និងបានណែនាំដល់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងចៅក្រម Cartwright នៅក្នុងគ្រប់ដំណាក់កាលនៃអាជីពរបស់ពួកគាត់[១៧]។ ទោះបីជាការសន្មត *ដើម្បីទាញទឡ្ហីករណ៍ (arguendo)* ដែលថាគោលការណ៍ក្រមសីលធម៌ទាំងនេះពុំ *ចង* កាតព្វកិច្ចពួកគាត់នៅកម្ពុជាក៏ដោយ និងទទួលស្គាល់ថាអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងសំដៅទៅ *ការប្រជុំ* ជាជាង*ការប្រាស្រ័យទាក់ទងការងារតាមរយៈសារអេឡិចត្រូនិក* ជាក់លាក់ក៏ដោយ ក៏ជាការគួរឲ្យសោកស្តាយដែលការប្រាស្រ័យទាក់ទងការងារទាំងនេះ បង្ហាញអំពីការពុំអើពើដោយធ្វេសប្រហែសចំពោះស្មារតីប្រសិនបើមិនមែនជាអំណាននៃគោលការណ៍ទាំងនេះទេនោះ ព្រមទាំងចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលផងដែរ។ យើងអាចនិយាយយ៉ាងសាមញ្ញថា ការធ្វើបែបនេះវាមិនត្រឹមត្រូវឡើយ។

១៩. បើទោះជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល បានបង្ហាញអំពីភាពមិនត្រឹមត្រូវនៃការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* រវាងចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញាក៏ដោយ ក៏ការណែនាំនេះពុំបានធ្វើអ្វីដើម្បីបន្ទុចបង្អាក់ចៅក្រម Cartwright និងសហព្រះរាជអាជ្ញាអន្តរជាតិ Cayley មុនពេលមេធាវីការពារក្តីអន្តរាគមន៍ឡើយ។ មេធាវីការពារក្តីបានដឹងដោយ

---

[១៧] *សូមមើល* សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ១៣-១៥, ២០-២១។

ថៃដន្យប៉ុណ្ណោះថា ការប្រាស្រ័យទាក់ទងការងារទាំងនេះបានកំពុងកើតមាន។ ប្រសិនបើចៅក្រម Cartwright ពុំបានផ្ញើសារអេឡិចត្រូនិករបស់គាត់ដោយភ័ន្តច្រឡំដោយប្រើបញ្ជីឈ្មោះអ្នកដែលត្រូវចែកចាយការជូនដំណឹងអំពីសំណុំរឿងនោះ ប្រហែលការសន្ទនា *ជាមួយភាគីតែម្ខាង* ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ប្រហែលជាបានបន្តទៀតមិនខាន។ ប្រសិនបើមិនអាចជាបណ្តឹងជំទាស់ចៅក្រម Cartwright ទេ សំណើជាជម្រើសមួយទៀតរបស់មេធាវីការពារក្តីនោះគឺសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចណែនាំមួយដល់ចៅក្រម Cartwright និងបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បញ្ចប់ និងបញ្ឈប់ ការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* ដោយមានការគំរាមដាក់ទណ្ឌកម្មដោយអនុលោមតាមវិធាន ៣៥ នៅក្នុងករណីមានការរំលោភ[១៨]។

## V. សំណើសុំឱ្យមានការប្រកាសលាតត្រដាង

២០. ដោយពុំគិតថា តើអង្គជំនុំជម្រះសាលាដំបូង ទទួលយកបណ្តឹងជំទាស់របស់មេធាវីការពារក្តីចំពោះចៅក្រម Cartwright ឬសម្រេចធ្វើការណែនាំដល់ចៅក្រម Cartwright និងបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ឈប់ និងបញ្ឈប់ការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* ដែរ ឬយ៉ាងណា មេធាវីការពារក្តីសូមស្នើឱ្យមានការលាតត្រដាងអំពីការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* របស់ចៅក្រម Cartwright ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ចាប់តាំងពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលជាកាលបរិច្ឆេទនៃសំណើសុំបំពេញកិច្ចស៊ើបសួរ។

២១. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា កិច្ចប្រជុំ *ជាមួយភាគីតែម្ខាង* រវាងចៅក្រម Cartwright និងសហព្រះរាជអាជ្ញាអន្តរជាតិ Cayley គឺជាការពុំសមស្រប។ វាហាក់បីដូចជាថា ការសម្រេចបញ្ឈប់កិច្ចប្រជុំ "រដ្ឋបាល" របស់លោក Rosandhaug សហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងចៅក្រម Cartwright ត្រូវបានធ្វើឡើង *បន្ទាប់ពី* សារអេឡិចត្រូនិករបស់ចៅក្រម

[១៨] ជាគោលការណ៍ ចៅក្រមយ៉ាងហោចណាស់ ស្ថិតនៅក្នុងយុត្តាធិការនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដរាបណាទង្វើដែលត្រូវបានចោទប្រកាន់របស់ចៅក្រមរូបនោះ នាំទៅដល់ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ក្នុងកម្រិតមួយដែលស្ថិតនៅក្នុងខ្លឹមសារនៃវិធាននោះ, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ១៤។

Cartwright បានលេចឡើង។ ការបញ្ឈប់កិច្ចប្រជុំទាំងនេះនៅក្នុងកាលៈទេសៈទាំងនេះ ជាជាងអនុញ្ញាតឱ្យមានការចូលរួមរបស់អង្គភាពគាំពារការការពារក្តី ឬក្រុមមេធាវីការពារក្តីក្នុងកិច្ចប្រជុំទាំងនេះ នាំឱ្យមានកង្វល់កាន់តែច្រើនថែមទៀតពាក់ព័ន្ធនឹងភាពសមស្របនៃការសម្រេចបែបនេះ។ មេធាវីការពារក្តីក៏បានទទួលការជូនដំណឹងថា ចៅក្រម Cartwright និងសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានចែករម្លែកបែបបទយុទ្ធសាស្ត្រ និងយុទ្ធវិធី ពាក់ព័ន្ធនឹងវិធីអនុវត្តបន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ ចៅក្រម Cartwright បានបញ្ចេញព័ត៌មានពាក់ព័ន្ធនឹងកិច្ចប្រជុំ *ជាមួយភាគីតែម្ខាង* ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងលោក Rosandhaug ទៅសារព័ត៌មានញូហ្សេឡង់[១៩] ដែលនេះបង្ហាញឱ្យឃើញពីឆន្ទៈរបស់គាត់ក្នុងការឆ្លើយទៅនឹងសំណួររបស់ប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែពុំឆ្លើយតបទៅនឹងភាគីលើបញ្ហានេះទេ។ មេធាវីការពារក្តីនៅតែមានកង្វល់យ៉ាងខ្លាំង និងស្របច្បាប់ពាក់ព័ន្ធនឹងឥទ្ធិពលមិនល្អរបស់កិច្ចប្រជុំ និងការប្រាស្រ័យទាក់ទងការងារទាំងនេះ មកលើលោក អៀង សារី ក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់ដើម្បីទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

២២. ការបញ្ចេញទាំងស្រុង និងច្បាស់លាស់អំពីការប្រាស្រ័យទាក់ទងការងារ *ជាមួយភាគីតែម្ខាង* របស់ចៅក្រម Cartwright ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ចាប់តាំងពីថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១១ គឺជាការចាំបាច់ ដើម្បីសម្រេចថាតើត្រូវមានសារណាបន្ថែមលើរឿងនេះដែរឬទេ។ ការបញ្ចេញការប្រាស្រ័យទាក់ទងទាំងស្រុងនឹងលើកកម្ពស់តម្លាភាព និងសង្គតិភាពនៃដំណើរការនីតិវិធី ដែលបង្កើនទំនុកចិត្តមកលើ អ.វ.ត.ក ក្នុងនាមជាតុលាការគំរូមួយ។

---

[១៩] *សូមមើល* Julia Wallce, *សារអេឡិចត្រូនិកពីចៅក្រម ទៅព្រះរាជអាជ្ញា បង្កើតឱ្យមានការជជែកដេញដោលជាថ្មីនៅសាលាក្តីខ្មែរក្រហម*, CAMBODIA DAILY, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២, ទំព័រ ២១៖ "កាលពីខែ កុម្ភៈ [ឆ្នាំ ២០១២ ចៅក្រម Cartwright] បានផ្តល់កិច្ចសម្ភាសន៍មួយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយដែលមានមូលដ្ឋាននៅប្រទេសញូហ្សេឡែន ដែលក្នុងនោះគាត់បានការពារកិច្ចប្រជុំទាំងនោះ ដែលគាត់បានមានប្រសាសន៍ថា អ.ស.ប បានស្នើគាត់ឱ្យចូលរួម។ "ខ្ញុំបានប្រកែកអស់រយៈពេលមួយចំនួន ប៉ុន្តែខ្ញុំបានយល់ថា ជាការសំខាន់ ដូច្នេះយើងជួបប្រជុំគ្នាដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ៗ ដូចជាថវិកាសម្រាប់តុលាការ, បញ្ហាបុគ្គលិក, បញ្ហាបច្ចេកវិទ្យាព័ត៌មាន បញ្ហាប្រភេទទាំងនេះ" ចៅក្រម Cartwright បានប្រាប់វិបសាយ Scoop.co.nz"។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្ដីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. **ដកហូតសិទ្ធិ**របស់ចៅក្រម Cartwright ដោយអនុលោមតាមវិធាន ៣៤(២) ឬ ជាជម្រើសមួយផ្សេងទៀត

ខ. **ណែនាំដល់**ចៅក្រម Cartwright និង**បង្គាប់**ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ឈប់ និងបញ្ឈប់ការប្រាស្រ័យទាក់ទងការងារ និងកិច្ចប្រជុំ *ជាមួយភាគីតែម្ខាង* ជាបន្ទាន់ និងត្រូវចម្លងទៅអ្នកតំណាងមួយរូបពីអង្គភាពគាំពារការការពារក្ដី ឬក្រុមមេធាវីការពារក្ដី តាមការសមស្របស្ដីពីការប្រាស្រ័យទាក់ទងការងារទាក់ទិននឹង អ.វ.ត.ក ទាំងអស់នៅថ្ងៃមុខ រវាងពួកគាត់ និង ក្នុងករណីណាក៏ដោយ

គ. **ណែនាំ**ចៅក្រម Cartwright និង**បង្គាប់**សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ឲ្យលាតត្រដាងអំពីការប្រាស្រ័យទាក់ទងការងារទាំងអស់ *ជាមួយភាគីតែម្ខាង* រវាងពួកគាត់ ចាប់តាំងពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ រួមបញ្ចូលទាំងលិខិតឆ្លើយឆ្លងទាំងអស់ និងទាក់ទិននឹងកិច្ចប្រជុំ *ជាមួយភាគីតែម្ខាង* ទាំងចំនួននៃការប្រជុំដែលត្រូវបានធ្វើ កាលបរិច្ឆេទនៃកិច្ចប្រជុំ របៀបវារៈនៃការប្រជុំ និងវិធានការទាំងឡាយដែលត្រូវបានអនុវត្តនៅឯកិច្ចប្រជុំ និងដោយអនុលោមតាមកិច្ចប្រជុំទាំងនេះ។

សូមអង្គជំនុំជម្រះមេត្តាទទួលយកបណ្ដឹងនេះដោយក្ដីគោរព។

________________ ______________________

អាង ឧត្ដម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២